ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
AGRICULTURAL AND RURAL DEVELOPMENT BANK
ដើម្បីកសិករនិងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម

# អាជីវកម្ម
# ចិញ្ចឹមមាន់ស្រែសាច់





រៀបចំដោយ
**គណៈកម្មការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាល នៃ**
**ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម** (ARDB)
ខែធ្នូ ឆ្នាំ២០២៤

023 220 811
023 220 810
095 416 878
# 168, Street 7, Prek Leap Village, Sangkat Prek Leap, Khan Chroy Changva, Phnom Penh

# មាតិកា

**១-សេចក្តីផ្តើម** ........................................ ១
**២-លក្ខណៈទូទៅ** ........................................ ១
**៣-ដំណើរការចិញ្ចឹម** ........................................ ២
៣-១-ការជ្រើសរើសកូនមាន់អាយុ១ថ្ងៃមកចិញ្ចឹម ........................................ ២
៣-២-ការសាងសងទ្រុង និងទីធ្លាចិញ្ចឹម ........................................ ៣
៣-៣-ស្នូកទឹក ........................................ ៥
៣-៤-ស្នូកចំណី ........................................ ៥
៣-៥-ការថែទាំ និងការធ្វើអនាម័យ ........................................ ៦
៣-៦-កម្មវិធីវ៉ាក់សាំងមាន់ស្រែសាច់ ........................................ ៩
**៤-គម្រោងអាជីវកម្មចិញ្ចឹមមាន់ស្រែសាច់** ........................................ ៩
៤-១-ចំណាយលើការចាប់ផ្តើមអាជីវកម្មដំបូង ........................................ ៩
៤-២-គម្រោងចំណាយ-ចំណូលលម្អិត និងលទ្ធផល ........................................ ១០
៤-៣-លទ្ធភាពចំណេញក្នុង១វគ្គ ដោយផ្អែកលើនិន្នាការតម្លៃ ........................................ ១១
**៥-ហានិភ័យ វិធានការ និងអនុសាសន៍** ........................................ ១១
**៦-សេចក្តីសន្និដ្ឋាន** ........................................ ១៣

## ១-សេចក្តីផ្តើម

ការចិញ្ចឹមមាន់ស្រែសាច់លក្ខណៈគ្រួសារខ្នាតមធ្យម គឺជាមុខរបរមួយដែលពេញនិយមសម្រាប់កសិករដែលអាចទទួលបានប្រាក់ចំណូលសមរម្យសម្រាប់ទ្រទ្រង់សេដ្ឋកិច្ចគ្រួសារ។ ការចិញ្ចឹមមាន់ស្រែសាច់ គឺមានភាពងាយស្រួលដោយពុំទាមទារការប្រើប្រាស់សម្ភារៈ ឬឧបករណ៍ច្រើនដែលមានតម្លៃខ្ពស់ឡើយ រីឯការផ្តល់ចំណីវិញគឺអាចផ្តល់ជាចំណីផ្សំស្រេច ចំណីលាយផ្សំដោយខ្លួនឯង ឬលែងឱ្យដើរស៊ីចំណីនៅតាមទីវាលក្បែរៗផ្ទះ។ ជាមួយគ្នានេះកសិករក៏អាចរៀបចំស្ទួនដំណាំបន្លែសម្រាប់ជាចំណីផ្សំដើម្បីកាត់បន្ថយការចំណាយលើការទិញចំណីពីខាងក្រៅផងដែរ។

មុនចាប់ផ្តើមប្រកបរបរចិញ្ចឹមមាន់ស្រែសាច់ទោះបីការចិញ្ចឹមជាលក្ខណៈគ្រួសារក្តី កសិករគួរយល់ដឹងឱ្យបានច្បាស់នូវបច្ចេកទេសចិញ្ចឹម ជាពិសេសបច្ចេកទេសថ្មីៗដែលធន់នឹងបម្រែបម្រួលអាកាសធាតុដូចជាការផ្តល់កម្តៅ ការជ្រើសរើសពូជ ការសាងសង់ទ្រុង ការផ្តល់ចំណី ការថែទាំ និងការការពារ ព្យាបាលជំងឺមាន់ជាដើមទើបអាចទទួលបានផលល្អ និងអាចជួយកាត់បន្ថយលើការចំណាយថ្លៃដើមចិញ្ចឹម។

## ២-លក្ខណៈទូទៅ

មាន់ស្រែសាច់ដែលកសិករនិយមចិញ្ចឹម និងមានតម្លៃខ្ពស់លើទីផ្សារត្រូវមានលក្ខណៈសម្បត្តិដូចជា÷ មានសម្បុរត្រសក់ និងស្វាយ មានស្បែកពណ៌លឿង ជើងលឿង ឬល្មៀត មានរោមក្រាស់ ធំធាត់លឿន (ជាមាន់ដែលមានអាយុត្រឹម ៣.៥ ទៅ ៤.៥ខែ មានទម្ងន់ ១.២ ទៅ ១.៥គក្រ) មានរោមដុះពេញខ្លួនក្រាស់ល្អ។



## ៣-ដំណើរការចិញ្ចឹម

### ៣-១-ការជ្រើសរើសកូនមាន់មកចិញ្ចឹម

កន្លងមកការទិញកូនមាន់ដែលមានអាយុ ២១ ថ្ងៃយកមកចិញ្ចឹមតែងមានបញ្ហាច្រើនដោយសារកូនមាន់ពុំទទួលបានកម្មវិធីវ៉ាក់សាំងត្រឹមត្រូវ និងគ្រប់ចំនួន។ តែបច្ចុប្បន្ន កសិករច្រើនជ្រើសរើសកូនមាន់អាយុ ១ថ្ងៃមកចិញ្ចឹម។ ការចិញ្ចឹមកូនមាន់អាយុ ១ថ្ងៃ មានគុណសម្បត្តិ និងគុណវិបត្តិដូចខាងក្រោម÷

**គុណសម្បត្តិ÷**

- កូនមាន់អាយុ ១ថ្ងៃអាចចិញ្ចឹមខ្លួនដោយខ្លួនឯងបាន ដោយប្រើនូវសារធាតុអាហារជាតិក្រហមក្នុងខ្លួនរបស់វាដូច្នេះក្នុងរយៈពេល២ ឬ៣ថ្ងៃ កូនមាន់មិនត្រូវការចំណី ឬទឹកក្នុងអំឡុងពេលដឹកជញ្ជូនយកទៅកន្លែងថ្មីទេ
- កូនមាន់អាយុ១ថ្ងៃមានតម្លៃធូរថ្លៃជាងកូនមាន់ដែលមានអាយុ ២១ថ្ងៃ
- អាចធ្វើកម្មវិធីវ៉ាក់សាំងដោយខ្លួនឯង ប្រកបដោយទំនុកចិត្ត (ដឹងពីចំនួនដងជាក់ច្បាស់)។

**គុណវិបត្តិ÷**

- ក្នុងពេលដឹកកូនមាន់យកទៅកន្លែងថ្មីអាចមានគ្រោះថ្នាក់ខ្លះៗដូចជា កូនមាន់មានការថប់ខ្យល់ដែលបណ្តាលមកពីអាកាសធាតុក្តៅពេក ឬត្រជាក់ពេក នឹងអាចមានអត្រាបាត់បង់ខ្ពស់ បើពុំមានយល់ពីបច្ចេកទេសថែទាំក្នុងការដឹកជញ្ជូនច្បាស់លាស់។
- សម្រាប់កូនមាន់មួយក្រុមមានចំនួន២៥ក្បាល ត្រូវដាក់ក្នុងកេស ឬប្រអប់ដែលបង្កើតបាននូវកម្តៅគ្រប់គ្រាន់ ប្រអប់នោះត្រូវចោះឱ្យមានរន្ធដើម្បីឱ្យមានខ្យល់ចេញចូលបានល្អ។ ចំណី និងទឹកចាំបាច់ត្រូវផ្តល់ឱ្យកូនមាន់ បើសិនជាមានការពន្យាពេលក្នុងការដឹកជញ្ជូនលើសពី ២ទៅ ៣ថ្ងៃ។

***លក្ខណៈសម្បត្តិរបស់កូនមាន់ដែលត្រូវជ្រើសរើសយកមកចិញ្ចឹម÷***

- មានអាយុដំណាលៗគ្នា ញាស់ក្នុងថ្ងៃតែមួយ
- មានទំហំ ទម្ងន់ និងពណ៌សម្បុរដូចៗគ្នា
- មានរោមទន់ភ្លឺរលោង ជើងមូលរលោង មិនស្វិត
- មានកែវភ្នែកភ្លឺថ្លា សំឡេងច្បាស់ រហ័សរហួន ពុំមានលាមកស្អិតជាប់គូទ
- មេបាមិនជាន់ឈាម ជាពូជស្អួត ធំធាត់លឿន ស្បែកនិងជើងមានពណ៌លឿង

### ៣-២-ការសាងសង់ទ្រុង និងទីធ្លាចិញ្ចឹមមាន់

ទ្រុងមាន់ត្រូវមានលក្ខណៈសមស្របមួយចំនួនដូចតទៅ÷

- ទ្រុងត្រូវសង់បែរមុខចេញពីទិសរបស់ខ្យល់ ប៉ុន្តែត្រូវធ្វើយ៉ាងណាឱ្យខ្យល់អាចចេញចូលបានល្អ
- ការពារកុំឱ្យត្រូវកម្តៅព្រះអាទិត្យខ្លាំងពេក
- កម្រាលត្រូវធ្វើឱ្យទឹកអាចហូរចេញបាន ដើម្បីការពារកុំឱ្យសើម
- ការចិញ្ចឹមមាន់នៅតំបន់អាកាសធាតុក្តៅ ត្រូវធ្វើជម្រក និងដំបូលបាំងពីលើឱ្យបានល្អ ហើយបើកចំហរឱ្យមានពន្លឺចេញចូលបានគ្រប់គ្រាន់។

#### ក-ការត្រួតពិនិត្យសីតុណ្ហភាព

សីតុណ្ហភាពក្តៅពេក ឬត្រជាក់ពេក បង្កើតឱ្យមានភាពតានតឹងក្នុងទ្រុងមាន់ ការសាងសង់ទ្រុងទៅតាមលក្ខណៈបច្ចេកទេស គឺអាស្រ័យទៅលើលក្ខខណ្ឌក្នុងស្រុក

#### ខ-ការធ្វើឱ្យខ្យល់ចេញចូល

ចលនាខ្យល់ចេញចូលនៅក្នុងទ្រុងជារឿងចាំបាច់ក្នុងការការពារកុំឱ្យមាន់ថប់ខ្យល់សម្រាប់ដកដង្ហើម ទ្រុងចិញ្ចឹមមាន់មិនត្រូវសង់ឡើងដោយមានព្រៃ គុម្ពោត ឬអគារនៅបាំងខ្យល់ចេញចូលឡើយ។ ចំពោះទ្រុងចិញ្ចឹមមាន់បែបពាណិជ្ជកម្មត្រូវសាងសង់ទ្រុងឱ្យខ្យល់ចេញចូលល្អ ឬដាក់កង្ហារ។

#### គ-ការត្រួតពិនិត្យសំណើម

ករណីមានសំណើមឡើងខ្ពស់ក្នុងរដូវភ្លៀង ជាហេតុធ្វើឱ្យមាន់អាចមានបញ្ហាជំងឺកើតឡើង ដូច្នេះកសិករត្រូវត្រួតពិនិត្យសំណើមនៅក្នុងទ្រុងចិញ្ចឹមមាន់ឱ្យបានទៀងទាត់ និងធ្វើចង្អូរសម្រាប់បង្ហូរទឹកចេញពីកម្រាលទ្រុង ដែលអាចកាត់បន្ថយនូវហានិភ័យសំណើមបានល្អ។

#### ឃ-ទីធ្លាចិញ្ចឹម

ការដាក់មាន់ចិញ្ចឹមក្នុងទ្រុងច្រើនក្បាលពេកបណ្តាលឱ្យមានបរិយាកាសស្អុះស្អាប់ និងមិនផ្តល់ផលបានល្អឡើយ។ តម្រូវការទំហំទ្រុងជាអប្បបរិមាសម្រាប់អាកាសធាតុសមរម្យ (មិនក្តៅពេកមិនត្រជាក់ពេក) មានខ្យល់អាចចេញចូលគ្រប់គ្រាន់ និងស្របទៅតាមអាយុរបស់មាន់គឺ÷ មាន់អាយុ ៦អាទិត្យ ត្រូវដាក់១៥ក្បាល/ម៉ែត្រការ៉េ មាន់អាយុ ១៦អាទិត្យត្រូវដាក់ ៥ក្បាល/ម៉ែត្រការ៉េ ហើយអាយុលើសពីនេះត្រូវដាក់ ៣ទៅ៤ក្បាល/ម៉ែត្រការ៉េ ឬបង្កើនទំហំឱ្យធំជាងនេះកាន់តែល្អ។

## ង- ការធ្វើទ្រុង

ត្រូវធ្វើទ្រុងមាន់ទៅតាមសម្ភារៈ និងវត្ថុធាតុដើមដែលមាននៅក្នុងស្រុកងាយស្រួលរក មានតម្លៃធូរថ្លៃ ហើយត្រូវសង់ទៅតាមគំរូប្លង់ទ្រុងចិញ្ចឹមមាន់។

## ច- ដំបូល

ដំបូលសម្រាប់ការពារទឹកភ្លៀង អាចប្រើប្រាស់ស្លឹកត្នោត ស្បូវ ស័ង្កសី ។ល។ នៅរដូវក្តៅត្រូវធ្វើសំយ៉ាបទ្រុង ដើម្បីការពារការជះកម្តៅខ្លាំងពេក និងធ្វើយ៉ាងណាឱ្យមានពន្លឺថ្ងៃចូលគ្រប់គ្រាន់នៅរដូវរងារ។




## ឆ- កម្រាល

ប្រភេទនៃកម្រាលប្រែប្រួលទៅតាមសណ្ឋានផ្សេងៗគ្នារួមមានកម្រាលផ្ទាល់ដី និងកម្រាលផុតពីដី ដែលធ្វើអំពីបន្ទះឈើ ឫស្សី សំណាញ់ដែក ឬជ័រ ហើយត្រូវគិតគូរលើភាពងាយស្រួលក្នុងការសម្អាតលាមក។

## ៣-៣-ស្នូកទឹក

ត្រូវមានការសម្អាតស្នូកទឹក និងមានទឹកត្រជាក់សម្រាប់មាន់ផឹកគ្រប់គ្រាន់ ជាទូទៅមាន់ត្រូវការផឹកទឹករៀងរាល់១៥-២០នាទីម្តង។ទឹកដែលផ្តល់ត្រូវមានអនាម័យ ស្នូកទឹកតម្រូវទៅតាមអាយុ និងកម្ពស់របស់មាន់។ ស្លែចាប់ផ្តើមកាន់យ៉ាងឆាប់រហ័សបំផុត បើសិនជាមិនបានសម្អាតវាឱ្យបានញឹកញាប់ទេនោះ បញ្ហានេះអាចជាជម្រកមេរោគ ដើម្បីសម្អាតស្នូកទឹកឱ្យបានស្អាតត្រូវប្រើជាមួយច្រាស់ដុស។






## ៣-៤-ស្នូកចំណី

ស្នូកចំណីមាន់អាចត្រូវបានធ្វើឡើងអំពីឈើ ឬស្សី ឬអាចប្រើប្រាស់ស្នូកចំណីដែលទិញពីទីផ្សារ។ កសិករត្រូវដាក់ស្នូកចំណីរាយជាជួរឱ្យបានច្រើនគ្រប់គ្រាន់ ដើម្បីឱ្យមាន់ស៊ីចំណីបានក្នុងពេលជាមួយគ្នា មិនដូច្នេះទេមាន់ដែលខ្សោយនឹងងាប់ ឬអាចក្រិន ធំធាត់មិនស្មើគ្នា។ គម្លាតចន្លោះដែលគួរតម្រាប់ស្នូកសម្រាប់មាន់គឺ៖ កូនមាន់អាយុ០-៨សប្តាហ៍ ត្រូវទុកចន្លោះ ២,៥ស.ម/ក្បាល មាន់ដែលមានអាយុពី ៩-១៦សប្តាហ៍ ត្រូវទុកចន្លោះ ៦,៧ស.ម/ក្បាល មាន់សម្រាប់ទុកជាមេ បាបង្កាត់ពូជ ១០,២ស.ម/ក្បាល។





### ៣-៥-ការថែទាំ និងការធ្វើអនាម័យ

កូនមាន់ត្រូវការចាំបាច់នូវកំដៅ ខ្យល់បរិសុទ្ធ ចំណីអាហារ និងទឹក។ នៅក្នុងទ្រុង ចលនារបស់កូនមាន់អាចបញ្ជាក់ពីកំដៅដែលបានផ្តល់ដល់កូនមាន់ ÷




ដាក់អំពូលពន្លឺភ្លើងក្រហមព្យួរកម្ពស់ពីកម្រាល៤៥ស.មវាជាប្រភពកម្តៅសំខាន់សម្រាប់កូនមាន់តូចៗ។

ក្នុងអាទិត្យទី១ គេត្រូវធ្វើរបាំងព័ទ្ធជុំវិញកន្លែងក្រុងកូនមាន់ ដោយក្រដាសក្រាស់ ឬប្រដាប់ហ៊ុំ ដោយត្រូវដាក់ទែម៉ូម៉ែតតាមដានសីតុណ្ហភាពកំដៅ។ បើសិនជាកូនមាន់ប្រមូលផ្តុំគ្នាហើយយំជីបៗនោះបញ្ជាក់ឱ្យដឹងថា ច្បាស់ជាខ្វះកម្តៅ ដូច្នេះគេចាំបាច់ត្រូវផ្តល់កម្តៅបន្ថែម។ ប្រសិនបើកូនមាន់ចេញឆ្ងាយពីប្រភពកម្តៅនោះត្រូវធ្វើការបន្ថយកម្តៅបន្តិច។ ការយកចិត្តទុកដាក់ជាប្រចាំចំពោះកូនមាន់តូចៗ គឺជាបញ្ហាសំខាន់បំផុត។

#### ក- ការផ្តល់ចំណី

វត្ថុធាតុដើមសម្រាប់ផ្សំចំណីអាចផ្លាស់ប្តូរបានតាមអ្វីដែលមានក្នុងស្រុក តម្លៃសមរម្យ និងងាយស្រួលស្វែងរក តែត្រូវគោរពតាមគោលការណ៍អាយុមាន់ និងតម្រូវការប្រូតេអ៊ីនរបស់មាន់÷

-កូនមាន់អាយុ០១ថ្ងៃ ដល់១ខែ តម្រូវការប្រូតេអ៊ីនយ៉ាងតិច ២១%ក្នុងចំណីមាន់

-កូនមាន់អាយុ ១ខែ ដល់ចាប់លក់ តម្រូវការប្រូតេអ៊ីនយ៉ាងតិច ១៨%ក្នុងចំណីមាន់

-កូនមាន់ចាប់ពីអាយុ១ខែឡើង អាចប្រើចំណីផ្សំដែលអាចរកបានក្នុងតំបន់ដូចជា÷ កន្ទក់ ចុងអង្ករ កាកស្រាបៀរ ត្រកួន ចកអាសូឡា និងបន្លែបៃតងមួយចំនួនទៀត ជួយឱ្យការចំណាយថ្លៃដើមផលិតទាប។

 

### ខ-ការផ្តល់ទឹក

កូនមាន់ស្វែងរកទឹកផឹកនៅថ្ងៃញាស់ដំបូង កសិករចិញ្ចឹមមាន់មិនត្រូវដាក់កូនមាន់ឱ្យនៅឆ្ងាយពីស្នូកទឹកចន្លោះ១ម៉ែត្រក្នុងរយៈពេល ២សប្តាហ៍ដំបូងឡើយ។ ហើយបន្ទាប់មកមិនត្រូវឱ្យឆ្ងាយពីស្នូកទឹក ៣,៥ម៉ែត្រ។ ក្នុងអំឡុងសប្តាហ៍ដំបូង កូនមាន់ ១០០ក្បាល ត្រូវការទឹកចំនួន ២លីត្រក្នុងមួយថ្ងៃ ។ ទំហំនៃស្នូកទឹកត្រូវបានបង្កើនទៅតាមការធំធាត់របស់មាន់ និងត្រូវពិនិត្យមើលកុំឱ្យមានទឹកកំពប់លើកម្រាល។

### គ-ការគ្រប់គ្រង

ត្រូវបញ្ឈប់ការផ្តល់កម្តៅក្រោយពីកូនមាន់មានអាយុ៣សប្តាហ៍ ឬអាចផ្តល់កម្តៅក្នុងសភាពផ្សេងៗគ្នាអាស្រ័យទៅតាមតំបន់។ សារធាតុចិញ្ចឹមសំខាន់ៗទាំងអស់ត្រូវបានផ្តល់ឱ្យមាន់ដោយលាយក្នុងចំណី។ កម្រាលទ្រុងខាងក្រោម តាមធម្មតាមានកម្រាស់ពី ៥ ទៅ ១០ស.ម។ ប្រភេទនៃកម្រាលសម្រាប់ឱ្យមាន់ដេកត្រូវជ្រើសរើសអាស្រ័យទៅតាមតម្លៃ និងលទ្ធភាពដែលអាចរកបាននៅក្នុងស្រុក ។ សម្ភារៈដែលដាក់សម្រាប់ជាកម្រាលរួមមាន÷ រុក្ខជាតិតូចៗពុកផុយ ចំបើង ចំណាំងឈើតូចៗ ឬអាចម៍រណា (ប្រើបានតែ៤អាទិត្យតែប៉ុណ្ណោះ) កម្ទេចសម្បកសណ្តែកដី កាកអំពៅ ក្រដាសកាសែត និងដីខ្សាច់(នេះជាជម្រើសចុងក្រោយ)។ គួរធ្វើទ្រុងឱ្យបានធំបន្តិច ដើម្បីឱ្យកម្រាលមានភាពស្ងួតជានិច្ច។

### ឃ-កត្តាអនាម័យ

ត្រូវបោសសម្អាតទីធ្លា ទ្រុង កើបលាមកមាន់រៀងរាល់ព្រឹក ប្រើប្រាស់ថ្នាំសម្លាប់មេរោគដូចជា TH4, Glutaraldehyde ឬ Formades ដោយបាញ់ក្នុងទ្រុង ជុំវិញទ្រុង និងទីធ្លាឱ្យបានយ៉ាងតិច២ដង/សប្តាហ៍ លាងស្នូកទឹក ស្នូកចំណីយ៉ាងតិចឱ្យបាន១ដង/ថ្ងៃ (អាចសម្អាតដោយប្រើប្រាស់ទឹក និងសាប៊ូដើម្បីសម្លាប់មេរោគដែលបង្កដោយវីរុស និងបាក់តេរី)។

### ង-ការធ្វើប្រព័ន្ធជីវៈសុវត្ថិភាព និងការការពារ

ការការពារគឺជាគន្លឹះសំខាន់នៃការទប់ស្កាត់ជំងឺទាំងឡាយរបស់មាន់ ជាទូទៅការការពារអាចសម្រេចបាន យ៉ាងល្អប្រសើរដោយ÷

១- *ការចាក់ថ្នាំការពារប្រឆាំងនឹងជំងឺ*

២- *ការផ្តល់ចំណីដែលមានតុល្យភាពនូវសារធាតុចិញ្ចឹមគ្រប់គ្រាន់ ដូចជាវីតាមីនសារធាតុរ៉ែ អាស៊ីតអាមីណេ និងថាមពល ដើម្បីការពារជំងឺកង្វះសារធាតុចិញ្ចឹម* ។

៣- *គោលការណ៍អនាម័យដែលត្រូវអនុវត្តមាន÷*

ក- មិនត្រូវយកមាន់ចាស់ៗ ចូលក្នុងហ្វូងមាន់ក្មេងឡើយ

ខ- ហាមភ្ញៀវ(រួមទាំងអ្នកជិតខាង) បក្សីព្រៃ សត្វកកេរ ជាពិសេសអ្នកចិញ្ចឹមមាន់នៅកន្លែងផ្សេង ចូលទៅក្នុងទ្រុងចិញ្ចឹមមាន់

គ- បន្ទាប់ពីការចូលមើលទ្រុងមាន់អ្នកផ្សេង ពេលត្រឡប់មកវិញត្រូវសម្អាតខ្លួនប្រាណ ផ្លាស់ប្តូរសំលៀកបំពាក់ និងស្បែកជើងមុនចូលទៅក្នុងទ្រុងមាន់របស់ខ្លួន

ឃ- ត្រូវយកក្រដាសឡាំងកខ្វក់ បាវចំណី និងវត្ថុណាដែលកខ្វក់ផ្សេងៗទៀតចេញពីទ្រុងចិញ្ចឹមមាន់

ង- បង្កើតបែបបទ“ចូលទាំងអស់ ចេញទាំងអស់”ដើម្បីធ្វើឱ្យមានកន្លែងដាក់មាន់ទៅតាមអាយុខុសៗគ្នា ហើយដាក់មាន់ណាដែលមានអាយុស្មើគ្នា ឱ្យនៅជាមួយគ្នា ។

ច- មុននឹងនាំហ្វូងមាន់ថ្មីចូលត្រូវធ្វើអនាម័យទ្រុង ដោយទ្រុងត្រូវដាក់ហាលនឹងពន្លឺព្រះអាទិត្យ ដើម្បីសម្លាប់មេរោគ រយៈពេល ២សប្តាហ៍យ៉ាងតិច

ឆ- បើមានមាន់ងាប់ត្រូវនាំយកចេញពីក្នុងទ្រុងជាប្រញាប់ ដោយយកទៅដុតចោល ឬកប់ឱ្យជ្រៅ។

### ៣-៦-កម្មវិធីវ៉ាក់សាំងមាន់ស្រែសាច់

| អាយុមាន់ | ប្រភេទវ៉ាក់សាំង | ការការពារលើជំងឺ | ការប្រើប្រាស់ | កម្រិតប្រើ |
|---|---|---|---|---|
| ៣-៥ថ្ងៃ | ឡាសូតា Lasota | ញូវកាស | បន្តក់ភ្នែកច្រមុះ ឬមាត់ | ១ដំណក់ |
| ១៤ថ្ងៃ | អុត | អុត | ជួសស្លាប | ជួសស្លាបម្តង |
| ១៤ថ្ងៃ | ហ្គូមបូរ៉ូ | ហ្គូមបូរ៉ូ | បន្តក់ភ្នែក | ១ដំណក់ |
| ២១ថ្ងៃ | ញូវកាស | ញូវកាស | បន្តក់ភ្នែកច្រមុះ ឬមាត់ | ១ដំណក់ |
| ៤៥ថ្ងៃ | អាសន្នរោគ | អាសន្នរោគ | ចាក់សាច់ដុំទ្រូង | ០,២៥ សេសេ |

## ៤-គម្រោងអាជីវកម្មចិញ្ចឹមមាន់ស្រែសាច់

**កសិករ** ៖ ឃុំវត្តអង្គខាងជើង ស្រុកបន្ទាយមាស ខេត្តកំពត

**ទំហំផ្ទៃដីចិញ្ចឹម** ៖ ១៥ អា (១,៥០០ម៉ែត្រការ៉េ)

**ចំនួនមាន់ចិញ្ចឹម** ៖ ៥០០ ក្បាល

**របៀបចិញ្ចឹម** ៖ ក្នុងទីធ្លាព័ទ្ធសំណាញ់ជុំវិញ និងផ្តល់ចំណីក្រុមហ៊ុន លាយជាមួយចំណីផ្សំធម្មជាតិ

**ចំនួនទ្រុង** ៖ ទ្រុងចំនួន១ (ទំហំ ៥ម៉ x១៥ម៉) ប្រក់ស័ង្កសី

**ប្រភេទមាន់** ៖ ជាមាន់ស្រែសាច់ មានស្បែកលឿង ជើងលឿង រោមពណ៌ត្រសក់ ខ្មៅ និងស្វាយ

**ទិន្នផល** ៖ មាន់អាយុ ១២០ថ្ងៃ, ទម្ងន់មាន់សរុបដែលទទួលបាន ៦១៧គក្រ/៤៧៥ក្បាល (ទម្ងន់ជាមធ្យម ១,៣គក្រ / ក្បាល)

**តម្លៃ** ៖ តម្លៃក្នុងតំបន់ចន្លោះពី ១៥,០០០៛ ទៅ ១៩,០០០៛/គក្រ និងអាចឡើងដល់ ២០,០០០៛/គក្រ នៅរដូវកាលចូលឆ្នាំចិន ឬបុណ្យទាន

**ទីផ្សារ** ៖កសិករលក់មាន់សាច់ (រស់) ឱ្យឈ្មួញយកទៅចែកចាយបន្តក្នុងខេត្តកំពត កែប និងខេត្តក្រុងសីហនុជាដើម។

**អត្រាស្លាប់** ៖ អត្រាមាន់ស្លាប់មានចំនួន ៥%នៃចំនួនមាន់សរុប ( ស្លាប់ចំនួន ២៥ក្បាល)

### ៤-១-ចំណាយលើការចាប់ផ្តើមអាជីវកម្មដំបូង៖

| ចំណាយវិនិយោគលើការរៀបចំទ្រុង អំពូលកម្តៅ និងសម្ភារៈផ្សេងៗ | ចំណាយលើការចិញ្ចឹម-ថែទាំ (ចំណី និងវ៉ាក់សាំង) | **ចំណាយសរុបពេលចាប់ផ្តើមអាជីវកម្ម** |
|---|---|---|
| **2,425,000** រៀល | **7,509,800** រៀល | **9,934,800** រៀល |

### ៤-២-គម្រោងចំណាយ-ចំណូលលម្អិត និងលទ្ធផល៖

| **បរិយាយ** | **ឯកតា** | **ចំនួនឯកតា** | **តម្លៃ ១ឯកតា** | **ទឹកប្រាក់សរុប (៛)** | **ចំនួនសារវ័លស់** | **ទឹកប្រាក់សរុប (៛)** |
|---|---|---|---|---|---|---|
| **១-ចំណូលសរុប/វគ្គ** | | | | | | **10,497,500** |
| ចំណូលពីការលក់មាន់សាច់(អាយុ៤ខែ) (១,៣ គ.ក x៤៧៥ក្បាល) | គក្រ | 617,5 | 17,000 | 10,497,500 | | 10,497,500 |
| **២-ចំណាយសរុប = ចំណាយប្រែប្រួល + ចំណាយមិនប្រែប្រួល/ថេរ** | | | | | | **7,719,356** |

| | | | | | | |
|---|---|---|---|---|---|---|
| **២.គ.ចំណាយប្រែប្រួល** | | | | | | **7,509,800** |
| កូនមាន់ | ក្បាល | 500 | 3,000 | | | 1,500,000 |
| ចំណីក្រុមហ៊ុន | គក្រ | 800 | 2,166 | | | 1,732,800 |
| ចំណីផ្សំ (កន្ទក់ កាកស្រាបៀរ ចុងអង្ករ ដើមចេក ត្រកួន ចកអាសូឡា) | គក្រ | 1,900 | 800 | | | 1,520,000 |
| ថ្លៃអគ្គិសនី | kwh | 50 | 740 | | | 37,000 |
| ថ្នាំវីតាមីនលើកូនមាន់ | គក្រ | 1 | 20,000 | | | 20,000 |
| វ៉ាក់សាំងលើកូនមាន់ | ក្បាល | 500 | 500 | | | 250,000 |
| កម្លាំងពលកម្ម | ខែ | 4 | 600,000 | | | 2,400,000 |
| ថ្នាំទម្លាក់សត្វល្អិត | កញ្ចប់ | 1 | 10,000 | | | 10,000 |
| ថ្នាំសម្លាប់មេរោគ | ដប | 1 | 40,000 | | | 40,000 |
| **២.ខ.ចំណាយមិនប្រែប្រួល/ថេរ** | | | | **2,425,000** | | **209,556** |
| ទ្រុងកូនមាន់ក្រោមអាយុ២១ថ្ងៃ (៣ឆ្នាំ) | ទ្រុង | 10 | 20,000 | 200,000 | 9 | 22,222 |
| ទ្រុងមាន់សាច់ និងសំណាញ់ជុំវិញ (៥ឆ្នាំ) | ទ្រុង | 1 | 2,000,000 | 2,000,000 | 15 | 133,333 |
| ស្នូកទឹក (៥ឆ្នាំ) | ចំនួន | 10 | 6,000 | 60,000 | 15 | 4,000 |
| ស្នូកចំណី (៥ឆ្នាំ) | ចំនួន | 5 | 15,000 | 75,000 | 15 | 5,000 |
| អំពូលកម្តៅ (ប្រើបាន២វគ្គ) | ចំនួន | 15 | 6,000 | 90,000 | 2 | 45,000 |
| **៣-ចំណេញ/វគ្គ** | | | | | | **2,778,144** |
| **ថ្លៃដើមចំណាយសរុបលើមាន់១គក្រ = ប្រាក់ចំណាយសរុប/ទម្ងន់មាន់សរុប** | | | | | | **12,501** |
| **ចំណេញក្នុងមាន់១គក្រ = ចំណូលពីការលក់មាន់ក្នុង១គក្រ - ចំណាយថ្លៃដើមមាន់ក្នុង១គក្រ** | | | | | | **4,499** |
| **ចំណូលពីការលក់លាមក= លាមកមាន់ ៦០បាវ x៤,០០០៛/បាវ** | | | | | | **240,000** |
| **ចំណេញសរុបក្នុងវគ្គ (៤ខែ) = ចំណេញពីការលក់មាន់សាច់ + ចំណូលពីការលក់លាមក** | | | | | | **3,018,144** |

### ៤-៣-លទ្ធភាពចំណេញក្នុង១វគ្គ ដោយផ្អែកលើនិន្នាការតម្លៃ÷

ផ្អែកតាមនិន្នាការតម្លៃមាន់ស្រែសាច់កសិករអាចទទួលបានប្រាក់ចំណេញសមរម្យក្នុងរយៈពេលចិញ្ចឹមមាន់៤ខែ/វគ្គ ដោយមានតម្លៃលក់ចន្លោះចាប់ពី ១៥,០០០៛/គក្រ ដល់ ១៩,០០០៛/គក្រ÷

| តម្លៃលក់ | ទិន្នផល | ចំណូល | | ចំណាយសរុប | ចំណេញ-ខាត | |
|---|---|---|---|---|---|---|
| រៀល/គក្រ | គក្រ | លាមក | សរុប(រៀល) | រៀល | រៀល | % |
| 15,000 | 617.5 | 240,000 | 9,502,500 | 7,719,356 | 1,783,144 | 23% |
| 16,000 | 617.5 | 240,000 | 10,120,000 | 7,719,356 | 2,400,644 | 31% |
| 17,000 | 617.5 | 240,000 | 10,737,500 | 7,719,356 | 3,018,144 | 39% |
| 18,000 | 617.5 | 240,000 | 11,355,000 | 7,719,356 | 3,635,644 | 47% |
| 19,000 | 617.5 | 240,000 | 11,972,500 | 7,719,356 | 4,253,144 | 55% |
| 20,000 | 617.5 | 240,000 | 12,590,000 | 7,719,356 | 4,870,644 | 63% |

### ៥-ហានិភ័យ វិធានការ និងអនុសាសន៍÷

តាមរយៈនៃការចុះស្វែងយល់អាជីវកម្មនៅកសិដ្ឋានចិញ្ចឹមមាន់ស្រែសាច់នៅឃុំវត្តអង្គខាងជើង ស្រុកបន្ទាយមាស ខេត្តកំពតឃើញថា ការចិញ្ចឹមមាន់អាចជួបប្រទះនូវហានិភ័យមួយចំនួនជាយថាហេតុប៉ះពាល់ដល់ដំណើរការផលិតកម្ម ដូចនេះកសិករចិញ្ចឹមមាន់គួររៀបចំផែនការជាក់លាក់ដើម្បីកាត់បន្ថយ ឬគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាពខ្ពស់។

**ហានិភ័យចម្បងៗក្នុងការចិញ្ចឹមមាន់ស្រែសាច់រួមមានដូចខាងក្រោម÷**

| ល.រ | ប្រភេទហានិភ័យ | ការពិពណ៌នាពីហានិភ័យ | វិធានការ និងអនុសាសន៍ |
|---|---|---|---|
| ១ | ហានិភ័យផលិតកម្ម | ទិន្នផលដែលទទួលបានទាបជាងការរំពឹងទុកបណ្តាលមកពី÷<br>-ជាមាន់ពូជតូច<br>-ពុំសូវមានរោម<br>-ជំងឺដំណរពូជ<br>-ជាន់ឈាមពីជំនាន់មេបា<br>-ពុំមានកម្មវិធីវ៉ាក់សាំងត្រឹមត្រូវ | -សិក្សាប្រវត្តិពីកសិដ្ឋានមេបាមាន់ឱ្យបានច្បាស់លាស់<br>-ត្រូវរើសកូនមាន់ដែលមានសុខភាពល្អមានទំហំប៉ុនៗគ្នា មានរោមភ្លឺរលោង<br>-បាតជើងមិនមានដំបៅ ដំណើររហ័សរហួន<br>-សម្លេងឮច្បាស់ មិនស្អក<br>-មានកែវភ្នែកភ្លឺថ្លា<br>-តាមដានទម្ងន់មេបា និងប្រវត្តិដើមនៃការបង្កាត់ពូជ |

| | | | |
|---|---|---|---|
| | | កង្វះទីធ្លាដាំស្មៅ ត្រកួន បន្លែស្លឹកផ្សេងៗសម្រាប់ជាវត្ថុធាតុដើមផ្សំចំណី | -រៀបចំដាំស្មៅ ត្រកួន ចកអាសូឡា បន្លែផ្សេងៗ ជុំវិញបរិវេណចិញ្ចឹមមាន់ឱ្យបានច្រើន<br>-ទិញស្រូវ មើមដំឡូងមី ពោត យកមកសម្ងួតដើម្បីស្តុកទុក<br>-រៀបចំដាំដើមចេកឱ្យបានច្រើន ជាជម្រកសត្វមាន់ផង និងជាចំណីមាន់នៅរដូវក្តៅផងដែរ<br>-មានទឹកស្អាតសម្រាប់ផឹកគ្រប់គ្រាន់ជាប្រចាំ |
| ២ | **ហានិភ័យទីផ្សារ** | លទ្ធភាពនៃការបាត់បង់ទីផ្សារឬតម្លៃដែលទទួលបានទាបជាងការរំពឹងទុក តម្លៃទីផ្សារមាន់ស្រែសាច់ប្រែប្រួលមិនច្បាស់លាស់ ពិសេសនៅ រដូវសំបូរត្រីធម្មជាតិ | -មានលទ្ធភាពផ្គត់ផ្គង់មាន់សាច់ច្បាស់លាស់<br>-ត្រៀមទ្រុងសម្រាប់ចិញ្ចឹមមាន់ទុកលក់ជាមេបាពូជនៅពេលពិបាកលក់ជាមាន់សាច់<br>-ចងក្រងបណ្តុំអ្នកចិញ្ចឹមមាន់សាច់ដើម្បីមានបណ្តាញទីផ្សារច្រើន<br>-លក់រាយក្នុងភូមិ និងតាមកម្មវិធីបុណ្យទានផ្សេងៗ |
| ៣ | **ហានិភ័យហិរញ្ញវត្ថុ** | ការមិនមានសាច់ប្រាក់គ្រប់គ្រាន់ដើម្បីត្រៀមបម្រុងសម្រាប់ទប់ទល់នឹងហេតុការណ៍កើតឡើងដោយចៃដន្យ ដូចជា÷ ខ្វះថវិកានៅក្នុងដំណើរការចិញ្ចឹម ពេលខ្លះត្រូវបង្ខំចិត្តលក់មាន់សាច់ពុំទាន់គ្រប់ទម្ងន់ក្នុងតម្លៃទាប | -ត្រូវមានផែនការអាជីវកម្មច្បាស់លាស់<br>-ត្រូវមានទុនបម្រុងក្រៅពីទុនវិនិយោគ<br>-ត្រូវមានទុនដែលជាឥណទានមានអត្រាការប្រាក់ទាប |
| ៤ | **ហានិភ័យបរិស្ថាន** | ពេលមានសម្លេងរំខាន និងក្លិនស្អុយដល់អ្នកជិតខាង | -ត្រូវចិញ្ចឹមនៅក្នុងចម្ការ ឬឆ្ងាយផ្ទះប្រជាជនរស់នៅ<br>-ត្រូវធ្វើអនាម័យជាប្រចាំ ទុកដាក់លាមកមាន់ឱ្យបានត្រឹមត្រូវនិងរៀបចំប្រព័ន្ធជីវសុវត្ថិភាព |

## ៦-សេចក្តីសន្និដ្ឋាន ÷

ការចិញ្ចឹមមាន់ស្រែសាច់នៅតាមផ្ទះឬក្នុងចម្ការផ្ទាល់ខ្លួនជាជម្រើសដ៏ល្អ ដែលកសិករអាចរកចំណូលសម្រាប់ផ្គត់ផ្គង់គ្រួសារបានមួយផ្នែក។ បច្ចុប្បន្នមាន់ស្រែសាច់មានតម្លៃល្អលើទីផ្សារ ពិសេសនៅតាមខេត្តចំនួនដូចជា÷ ខេត្តតាកែវ កែប កំពត កំពង់ស្ពឺ ព្រះសីហនុ ដែលអាចឱ្យកសិករចិញ្ចឹមមាន់ទទួលបានប្រាក់ចំណេញសមរម្យ ជាសញ្ញាណមួយឱ្យកសិករចាប់យកមុខរបរចិញ្ចឹមមាន់ស្រែសាច់នេះជារបរអចិន្ត្រៃយ៍ ហើយក៏ជាឱកាសល្អសម្រាប់កសិករដែលកំពុងប្រកបរបរនេះគួរពង្រីកការចិញ្ចឹមនៅតាមផ្ទះ ឬកសិដ្ឋាន បង្កើនទាំងបរិមាណ និងគុណភាពដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារក្នុងស្រុក។ កសិករគួរជ្រើសរើសពូជមាន់ស្រុកមានភាពធន់នឹងជំងឺ ចិញ្ចឹមឆាប់ធំ ជើងពណិល្មៀត មានទីផ្សារនិងតម្លៃល្អ ព្រោះជាមាន់ដែលអ្នកបរិភោគនិយមទូទាំងប្រទេស។

## ប្រភពសិក្សាស្រាវជ្រាវ ÷


១. កសិករចិញ្ចឹមមាន់ស្រែសាច់នៅ ឃុំវត្តអង្គខាងជើង ស្រុកបន្ទាយមាស ខេត្តកំពត

២. ឯកសារគំរូបច្ចេកទេសចិញ្ចឹមមាន់ស្រុករបស់ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម

៣. សៀវភៅណែនាំបច្ចេកទេស កសិករចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ របស់ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ

៤. សៀវភៅណែនាំបច្ចេកទេសស្តីពីការចិញ្ចឹមមាន់ស្រុក (នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម)